ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ថ្ងៃចន្ទ ៩រោច ខែស្រាពណ៍ ឆ្នាំខាល ចត្វាស័ក ព.ស.២៥៦៦
រាជធានីភ្នំពេញ ថ្ងៃទី១៥ ខែសីហា ឆ្នាំ២០២២

គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត

## ប្រតិទិននៃការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ នីតិកាលទី៧ ឆ្នាំ២០២៣

| ល.រ | ភារកិច្ចត្រូវបំពេញ | កាលបរិច្ឆេទ |
|---|---|---|
| ១ | ការចុះឈ្មោះអ្នកសង្កេតការណ៍បោះឆ្នោតជាតិ និងអ្នកសារព័ត៌មានជាតិនៅ គ.ជ.ប | ថ្ងៃទី១ ខែមេសា-១២ ខែកក្កដា ឆ្នាំ២០២៣ |
| ២ | ការចុះឈ្មោះអ្នកសង្កេតការណ៍បោះឆ្នោតអន្តរជាតិ និងអ្នកសារព័ត៌មានអន្តរជាតិនៅ គ.ជ.ប | ថ្ងៃទី១ ខែមេសា-១៩ខែកក្កដា ឆ្នាំ២០២៣ |
| ៣ | ការចុះបញ្ជីគណបក្សនយោបាយឈរឈ្មោះបោះឆ្នោត និងបញ្ជីបេក្ខជននៅ គ.ជ.ប រយៈពេល ១៥ថ្ងៃ | ថ្ងៃទី២៤ ខែមេសា-៨ ខែឧសភា ឆ្នាំ២០២៣ |
| ៤ | ការប្ដឹងតវ៉ាទៅនឹងការបដិសេធការសុំចុះបញ្ជីគណបក្សទៅក្រុមប្រឹក្សាធម្មនុញ្ញ ក្នុងរយៈពេល ៥ថ្ងៃ | ថ្ងៃទី២៦ខែឧសភា ឆ្នាំ២០២៣ (ថ្ងៃចុងក្រោយ) |
| ៥ | ការដោះស្រាយពាក្យបណ្ដឹងដោយក្រុមប្រឹក្សាធម្មនុញ្ញ ក្នុងរយៈពេល ១០ថ្ងៃ | ថ្ងៃទី៥ខែមិថុនា ឆ្នាំ២០២៣ (ថ្ងៃចុងក្រោយ) |
| ៦ | ការចែកប័ណ្ណព័ត៌មានអ្នកបោះឆ្នោត | ថ្ងៃទី២៨ខែឧសភា-២៦ ខែមិថុនា ឆ្នាំ២០២៣ |
| ៧ | ការបិទផ្សាយបញ្ជីរាយនាមគណបក្សនយោបាយ និងបេក្ខជនឈរឈ្មោះតាមមណ្ឌលរាជធានី ខេត្ត | ថ្ងៃទី១៣ខែមិថុនា ឆ្នាំ២០២៣ (ថ្ងៃចុងក្រោយ) |
| ៨ | ការចុះឈ្មោះភ្នាក់ងារគណបក្សនយោបាយ ក្នុងរយៈពេល ៧ថ្ងៃ ក្រោយថ្ងៃបិទផ្សាយបញ្ជីរាយនាមគណបក្សនយោបាយ និងបេក្ខជនឈរឈ្មោះតាមមណ្ឌលរាជធានី ខេត្ត | ថ្ងៃទី២០ ខែមិថុនា ឆ្នាំ២០២៣ (ថ្ងៃចុងក្រោយ) |
| ៩ | ការបិទផ្សាយបញ្ជីឈ្មោះ ទីតាំងការិយាល័យបោះឆ្នោត និងបញ្ជីបោះឆ្នោតនៅ គឃ.សប | ថ្ងៃទី២៣ ខែមិថុនា ឆ្នាំ២០២៣ |
| ១០ | ការស្នើសុំ និងការចេញឯកសារបញ្ជាក់អត្តសញ្ញាណបម្រើឱ្យការបោះឆ្នោតតាមឃុំ សង្កាត់ ក្នុងរយៈពេល៣០ថ្ងៃ | ថ្ងៃទី២២ខែមិថុនា-២១ ខែកក្កដា ឆ្នាំ២០២៣ |
| ១១ | ការឃោសនាបោះឆ្នោត | ថ្ងៃទី១ ខែកក្កដា - ២១ ខែកក្កដា ឆ្នាំ២០២៣ |
| ១២ | ការបិទផ្សាយបញ្ជីបោះឆ្នោត និងលេខកូដការិយាល័យបោះឆ្នោត នៅការិយាល័យបោះឆ្នោត | ថ្ងៃទី២២ខែកក្កដា ឆ្នាំ២០២៣ |
| ១៣ | ការបោះឆ្នោត ការរាប់សន្លឹកឆ្នោត និងការបិទផ្សាយលទ្ធផលនៅការិយាល័យបោះឆ្នោត | ថ្ងៃទី២៣ខែកក្កដា ឆ្នាំ២០២៣ |
| ១៤ | ការប្រកាសផ្សាយលទ្ធផលបឋមនៃការបោះឆ្នោត | ថ្ងៃទី២៣-២៤ ខែកក្កដា ឆ្នាំ២០២៣ |
| ១៥ | ការប្ដឹងតវ៉ាទៅ គឃ.សប អំពីលទ្ធផលនៃការបោះឆ្នោត ឬភាពមិនប្រក្រតីនៅការិយាល័យបោះឆ្នោត | ថ្ងៃទី២៤ ខែកក្កដា ឆ្នាំ២០២៣ (យ៉ាងយូរត្រឹមម៉ោង ១១:៣០នាទី) |
| ១៦ | គឃ.សប សម្រេចលើពាក្យបណ្ដឹងត្រួតពិនិត្យបូកសរុបលទ្ធផល ធ្វើកំណត់ហេតុ និងបិទផ្សាយកំណត់ហេតុ | ថ្ងៃទី២៤-២៥ ខែកក្កដា ឆ្នាំ២០២៣ |
| ១៧ | ការប្ដឹងតវ៉ាទៅ គធ.ខប ក្នុងរយៈពេលយ៉ាងយូរ ២ថ្ងៃ បន្ទាប់ពីការសម្រេចរបស់ គឃ.សប | ថ្ងៃទី២៧ ខែកក្កដា ឆ្នាំ២០២៣ (ថ្ងៃចុងក្រោយ) |
| ១៨ | ការដោះស្រាយពាក្យបណ្ដឹងដោយ គធ.ខប ក្នុងរយៈពេលយ៉ាងយូរ ៣ថ្ងៃ បន្ទាប់ពីទទួលពាក្យបណ្ដឹង | ថ្ងៃទី៣០ខែកក្កដា ឆ្នាំ២០២៣ (ថ្ងៃចុងក្រោយ) |
| ១៩ | ការប្ដឹងតវ៉ាទៅ គ.ជ.ប ក្នុងរយៈពេលយ៉ាងយូរ ២ថ្ងៃ បន្ទាប់ពីការសម្រេចរបស់ គធ.ខប | ថ្ងៃទី១ ខែសីហា ឆ្នាំ២០២៣ (ថ្ងៃចុងក្រោយ) |
| ២០ | ការដោះស្រាយពាក្យបណ្ដឹងដោយ គ.ជ.ប ក្នុងរយៈពេលយ៉ាងយូរ ៣ថ្ងៃ បន្ទាប់ពីទទួលពាក្យបណ្ដឹង | ថ្ងៃទី៤ ខែសីហា ឆ្នាំ២០២៣ (ថ្ងៃចុងក្រោយ) |
| ២១ | ការប្រកាសលទ្ធផលបណ្ដោះអាសន្នដោយ គ.ជ.ប (ករណីគ្មានការបោះឆ្នោតសាជាថ្មី) | ថ្ងៃទី៥ ខែសីហា ឆ្នាំ២០២៣ |
| ២២ | ការប្ដឹងតវ៉ាទៅ គ.ជ.ប ឬក្រុមប្រឹក្សាធម្មនុញ្ញអំពីលទ្ធផលបណ្ដោះអាសន្ន ក្នុងរយៈពេលយ៉ាងយូរ ៧២ម៉ោង | ថ្ងៃទី៨ ខែសីហា ឆ្នាំ២០២៣ (ថ្ងៃចុងក្រោយ) |
| ២៣ | ការដោះស្រាយពាក្យបណ្ដឹងដោយ គ.ជ.ប ក្នុងរយៈពេលយ៉ាងយូរ ៧២ម៉ោង បន្ទាប់ពីបានទទួលពាក្យបណ្ដឹង | ថ្ងៃទី១១ ខែសីហា ឆ្នាំ២០២៣ (ថ្ងៃចុងក្រោយ) |
| ២៤ | ការប្ដឹងតវ៉ាទៅក្រុមប្រឹក្សាធម្មនុញ្ញក្នុងរយៈពេលយ៉ាងយូរ ៧២ម៉ោង បន្ទាប់ពីទទួលលិខិតបដិសេធរបស់ គ.ជ.ប | ថ្ងៃទី១៤ខែសីហា ឆ្នាំ២០២៣ (ថ្ងៃចុងក្រោយ) |
| ២៥ | ការដោះស្រាយពាក្យបណ្ដឹងដោយក្រុមប្រឹក្សាធម្មនុញ្ញ ក្នុងរយៈពេលយ៉ាងយូរពី ១០-២០ថ្ងៃ បន្ទាប់ពីបានទទួលពាក្យបណ្ដឹង | ថ្ងៃទី៣ ខែកញ្ញា ឆ្នាំ២០២៣ (ថ្ងៃចុងក្រោយ) |
| ២៦ | ការបោះឆ្នោតសាជាថ្មី (ប្រសិនបើមាន) | ថ្ងៃទី ១១ ខែកញ្ញា ឆ្នាំ២០២៣ (ថ្ងៃចុងក្រោយ) |
| ២៧ | ប្រកាសលទ្ធផលផ្លូវការ ការបែងចែកអាសនៈ និងការកំណត់បេក្ខជនជាប់ឆ្នោត (តាមករណីគ្មាន ឬមានបណ្ដឹង និងករណីគ្មានការបោះឆ្នោតសាជាថ្មី) | ថ្ងៃទី៩ ខែសីហា-ថ្ងៃទី៨ ខែកញ្ញា ឆ្នាំ២០២៣ |

វិថីរដ្ឋសភា សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន រាជធានីភ្នំពេញ កម្ពុជា
St., Ratsaphea Tonle Basac, Khan Chamkar Mon, Phnom Penh, Cambodia
ទូរស័ព្ទ : 023 235 271
អ៊ីម៉ែល : info@nec.gov.kh

គ.ជ.ប






# សៀវភៅ សម្រាប់ អ្នកបោះឆ្នោត






## ការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ នីតិកាលទី៧ ឆ្នាំ២០២៣
## នៅថ្ងៃអាទិត្យ ទី២៣ ខែកក្កដា ឆ្នាំ២០២៣

# ការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ នីតិកាលទី៧ ឆ្នាំ២០២៣



តើការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ នីតិកាលទី៧ ឆ្នាំ២០២៣ ប្រព្រឹត្តទៅនៅពេលណា?

*ការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ នីតិកាលទី៧ ប្រព្រឹត្តទៅនៅ**ថ្ងៃអាទិត្យ ទី២៣ ខែកក្កដា ឆ្នាំ២០២៣**។*

១ តើតំណាងរាស្ត្រ ត្រូវបានជ្រើសតាំងយ៉ាងដូចម្តេច?

២ តំណាងរាស្ត្រ ត្រូវបានជ្រើសតាំងដោយការបោះឆ្នោតជាទូទៅ ជាសកល ដោយសេរី ត្រឹមត្រូវ និងយុត្តិធម៌ ដោយស្មើភាព ដោយចំពោះ តាមវិធីជ្រើសរើសឆ្នោតជាសម្ងាត់។




១
តើការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ ធ្វើតាមប្រព័ន្ធណា?
២
ការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ ត្រូវធ្វើតាមប្រព័ន្ធសមាមាត្រ តាមរាជធានី ខេត្ត ដែលជាមណ្ឌលបោះឆ្នោត។


តើអាសនៈនៅក្នុងរដ្ឋសភា មានចំនួនប៉ុន្មាន? ហើយបែងចែកយ៉ាងដូចម្តេច?

អាសនៈនៅក្នុងរដ្ឋសភាមានចំនួន ១២៥ ដែលបែងចែកតាមមណ្ឌលរាជធានី ខេត្ត ដូចខាងក្រោម៖

| | | |
|---|---|---|
| ០១. | មណ្ឌលខេត្តបន្ទាយមានជ័យ | ចំនួន ៦ អាសនៈ |
| ០២. | មណ្ឌលខេត្តបាត់ដំបង | ចំនួន ៨ អាសនៈ |
| ០៣. | មណ្ឌលខេត្តកំពង់ចាម | ចំនួន ១០ អាសនៈ |
| ០៤. | មណ្ឌលខេត្តកំពង់ឆ្នាំង | ចំនួន ៤ អាសនៈ |
| ០៥. | មណ្ឌលខេត្តកំពង់ស្ពឺ | ចំនួន ៦ អាសនៈ |
| ០៦. | មណ្ឌលខេត្តកំពង់ធំ | ចំនួន ៦ អាសនៈ |
| ០៧. | មណ្ឌលខេត្តកំពត | ចំនួន ៦ អាសនៈ |
| ០៨. | មណ្ឌលខេត្តកណ្តាល | ចំនួន ១១ អាសនៈ |
| ០៩. | មណ្ឌលខេត្តកោះកុង | ចំនួន ១ អាសនៈ |
| ១០. | មណ្ឌលខេត្តក្រចេះ | ចំនួន ៣ អាសនៈ |
| ១១. | មណ្ឌលខេត្តមណ្ឌលគិរី | ចំនួន ១ អាសនៈ |
| ១២. | មណ្ឌលរាជធានីភ្នំពេញ | ចំនួន ១២ អាសនៈ |
| ១៣. | មណ្ឌលខេត្តព្រះវិហារ | ចំនួន ១ អាសនៈ |
| ១៤. | មណ្ឌលខេត្តព្រៃវែង | ចំនួន ១១ អាសនៈ |

| | | |
|---|---|---|
| ១៥. | មណ្ឌលខេត្តពោធិ៍សាត់ | ចំនួន ៤ អាសនៈ |
| ១៦. | មណ្ឌលខេត្តរតនគិរី | ចំនួន ១ អាសនៈ |
| ១៧. | មណ្ឌលខេត្តសៀមរាប | ចំនួន ៦ អាសនៈ |
| ១៨. | មណ្ឌលខេត្តព្រះសីហនុ | ចំនួន ៣ អាសនៈ |
| ១៩. | មណ្ឌលខេត្តស្ទឹងត្រែង | ចំនួន ១ អាសនៈ |
| ២០. | មណ្ឌលខេត្តស្វាយរៀង | ចំនួន ៥ អាសនៈ |
| ២១. | មណ្ឌលខេត្តតាកែវ | ចំនួន ៨ អាសនៈ |
| ២២. | មណ្ឌលខេត្តកែប | ចំនួន ១ អាសនៈ |
| ២៣. | មណ្ឌលខេត្តប៉ៃលិន | ចំនួន ១ អាសនៈ |
| ២៤. | មណ្ឌលខេត្តឧត្តរមានជ័យ | ចំនួន ១ អាសនៈ |
| ២៥. | មណ្ឌលខេត្តត្បូងឃ្មុំ | ចំនួន ៨ អាសនៈ |

# ការចុះឈ្មោះបោះឆ្នោត និងបញ្ជីបោះឆ្នោត

ការរៀបចំ ការគ្រប់គ្រង និងការប្រព្រឹត្តទៅនៃការពិនិត្យបញ្ជីឈ្មោះ និងការចុះឈ្មោះបោះឆ្នោត ឆ្នាំ២០២២ ត្រូវអនុវត្តតាម ច.ប.ត.រ និងបទបញ្ជា និងនីតិវិធីសម្រាប់ការពិនិត្យបញ្ជីឈ្មោះនិងការចុះឈ្មោះប្រចាំឆ្នាំ របស់ គ.ជ.ប។





តើ គ.ជ.ប បិទផ្សាយបញ្ជីបោះឆ្នោត និង
បញ្ជីឈ្មោះទីតាំងការិយាល័យបោះឆ្នោត
នៅពេលណា? និងនៅកន្លែងណា?

*គ.ជ.ប នឹងបិទផ្សាយបញ្ជីបោះឆ្នោត និងបញ្ជីឈ្មោះទីតាំងការិយាល័យបោះឆ្នោត នៅទីស្នាក់ការគណៈកម្មការឃុំ សង្កាត់រៀបចំការបោះឆ្នោត (**គឃ.សប**) **នៅថ្ងៃទី២៣ ខែមិថុនា ឆ្នាំ២០២៣** ហើយនិងបិទផ្សាយបញ្ជីបោះឆ្នោតនៅតាមការិយាល័យបោះឆ្នោត **នៅថ្ងៃទី២២ ខែកក្កដា ឆ្នាំ២០២៣** គឺ ១ថ្ងៃ មុនថ្ងៃបោះឆ្នោត។*

គ.ជ.ប បានផ្សព្វផ្សាយ
ជាសាធារណៈនូវបញ្ជីបោះឆ្នោត និងបញ្ជីឈ្មោះទីតាំង
ការិយាល័យបោះឆ្នោតតាមរយៈគេហទំព័រ គ.ជ.ប
voterlist.nec.gov.kh និងតាមរយៈកម្មវិធីទូរសព្ទដៃ
(App) NEC KH។



# លក្ខខណ្ឌសម្រាប់អ្នកបោះឆ្នោត



ដើម្បីបោះឆ្នោតបាន ប្រជាពលរដ្ឋទាំងពីរភេទ ត្រូវមានលក្ខខណ្ឌអ្វីខ្លះ?

ដើម្បីបោះឆ្នោតបានក្នុងការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ នីតិកាលទី៧ ឆ្នាំ២០២៣ នេះ ប្រជាពលរដ្ឋទាំងពីរភេទ ត្រូវមានលក្ខខណ្ឌ ដូចខាងក្រោម ៖

- មានឈ្មោះក្នុងបញ្ជីបោះឆ្នោតផ្លូវការដែលបានផ្តល់សុពលភាពដោយ គ.ជ.ប សម្រាប់បម្រើឱ្យការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ នីតិកាលទី៧ ឆ្នាំ២០២៣។
- មានអត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ (អ.ខ) ដែលមានសុពលភាព ឬឯកសារបញ្ជាក់អត្តសញ្ញាណបម្រើឱ្យការបោះឆ្នោត (ឯ.អ)។







អ.ខ ប្រភេទថ្មី ដែលមានសុពលភាព




ប្រជាពលរដ្ឋដែលស្នើសុំ **ឯ.អ** ត្រូវបំពេញលក្ខខណ្ឌ ដូចខាងក្រោម ៖

- ត្រូវស្នើសុំ **ឯ.អ** ក្នុងរយៈពេល ៣០ថ្ងៃ មុនថ្ងៃបោះឆ្នោត និងបញ្ចប់ ១ថ្ងៃ មុនថ្ងៃបោះឆ្នោត វេលាម៉ោង ១៧:៣០ នាទីល្ងាច ជាកំហិត
- ត្រូវបង្ហាញខ្លួនដោយផ្ទាល់នៅចំពោះមុខ **គឃ.សប** នៃឃុំ សង្កាត់ដែលសាមីខ្លួនមានឈ្មោះក្នុងបញ្ជីបោះឆ្នោតផ្លូវការ និងត្រូវបោះឆ្នោត
- ត្រូវបំពេញពាក្យស្នើសុំ និងត្រូវផ្តិតស្នាមម្រាមដៃនៅចំពោះមុខប្រធាន គឃ.សប





- ត្រូវផ្តល់ស្នាមម្រាមដៃតាមការណែនាំរបស់សមាជិក គឃ.សប ទទួលបន្ទុកលើការងាររដ្ឋបាល និងថតរូបសម្រាប់ការផ្ទៀងផ្ទាត់ និងទាញទិន្នន័យពីបញ្ជីបោះឆ្នោតផ្លូវការក្នុងប្រព័ន្ធគ្រប់គ្រងទិន្នន័យអ្នកបោះឆ្នោត និងបញ្ជីបោះឆ្នោត។
- បន្ទាប់ពី គឃ.សប ផ្ទៀងផ្ទាត់ភាពត្រឹមត្រូវ រវាងពាក្យស្នើសុំជាមួយទិន្នន័យក្នុងបញ្ជីបោះឆ្នោតផ្លូវការ និងបោះពុម្ពទម្រង់ ឯ.អ រួចចុះហត្ថលេខា និងបោះត្រា គឃ.សប រួចមក អ្នកស្នើសុំត្រូវយកទម្រង់ ឯ.អ ពី គឃ.សប ទៅជួបមេឃុំ ចៅសង្កាត់ ដើម្បីចុះហត្ថលេខា និងបោះត្រាឃុំ សង្កាត់ ផ្តល់សុពលភាពប្រើប្រាស់ជាផ្លូវការ ជាការស្រេច។

# ដំណើរប្រព្រឹត្តទៅនៃការបោះឆ្នោត

១ និយាយអ៊ីចឹង!
តើនៅថ្ងៃបោះឆ្នោត អ្នកបោះឆ្នោត ត្រូវដឹងពីព័ត៌មានអ្វីខ្លះ?

២ នៅថ្ងៃបោះឆ្នោត អ្នកបោះឆ្នោតត្រូវដឹងពីទីតាំងការិយាល័យបោះឆ្នោតរបស់ខ្លួនជាមុនសិន។



*ការិយាល័យបោះឆ្នោតចាប់ផ្តើមបើកឱ្យអ្នកបោះឆ្នោតចូលទៅបោះឆ្នោតចាប់ពី**ម៉ោង ៧:០០ នាទីព្រឹក ដល់ម៉ោង ១៥:០០ នាទីរសៀល** ហើយការបោះឆ្នោតត្រូវធ្វើតែ ១ថ្ងៃប៉ុណ្ណោះ។*



តើពេលទៅដល់ការិយាល័យបោះឆ្នោត អ្នកបោះឆ្នោត ត្រូវធ្វើយ៉ាងដូចម្តេចខ្លះ?

- *ប្រសិនបើអ្នកបោះឆ្នោតមានបណ្ណព័ត៌មានអ្នកបោះឆ្នោត ពេលទៅដល់ការិយាល័យបោះឆ្នោត គាត់អាចយកបណ្ណព័ត៌មាននោះ ជូនទៅលេខាធិការ ដើម្បីពិនិត្យមើលលេខរៀងឈ្មោះរបស់គាត់ក្នុងបញ្ជីបោះឆ្នោត។*

– ក្នុងករណីអ្នកបោះឆ្នោតពុំមានបណ្ណព័ត៌មានអ្នកបោះឆ្នោត នៅពេលទៅដល់ការិយាល័យបោះឆ្នោត អ្នកបោះឆ្នោតត្រូវទៅរកមើលឈ្មោះរបស់ខ្លួនក្នុងបញ្ជីបោះឆ្នោត ដែលត្រូវបានបិទនៅមុខការិយាល័យបោះឆ្នោត ដើម្បីឱ្យប្រាកដថា ឈ្មោះរបស់ខ្លួនស្ថិតក្នុងបញ្ជីបោះឆ្នោតនៃការិយាល័យបោះឆ្នោតនោះ។

បើរកឃើញឈ្មោះរបស់ខ្លួន
អ្នកបោះឆ្នោតត្រូវចាំលេខរៀង ដើម្បីងាយស្រួលប្រាប់
លេខាធិការ ក្នុងការរកឈ្មោះ នៅពេលចូលក្នុង
ការិយាល័យបោះឆ្នោត។





អ្នកបោះឆ្នោតស្វែងរកឈ្មោះក្នុងបញ្ជីបោះឆ្នោត ដែលបិទនៅមុខ
ការិយាល័យបោះឆ្នោត

នៅពេលបានចូលក្នុងការិយាល័យបោះឆ្នោត អ្នកបោះឆ្នោតត្រូវទៅជួបលេខាធិការមុនគេ។

- លេខាធិការត្រួតពិនិត្យម្រាមដៃអ្នកបោះឆ្នោត ដើម្បីបញ្ជាក់ឱ្យប្រាកដថា គ្មានស្នាមទឹកខ្មៅលុបមិនជ្រះ។
- អ្នកបោះឆ្នោត ត្រូវប្រគល់ **អ.ខ** ឬ **ឯ.អ** និងបណ្ណព័ត៌មានអ្នកបោះឆ្នោតឱ្យលេខាធិការ ដើម្បីពិនិត្យផ្ទៀងផ្ទាត់ឈ្មោះ និងទិន្នន័យពាក់ព័ន្ធនៅក្នុងបញ្ជីបោះឆ្នោត។

ក្នុងករណី អ្នកបោះឆ្នោតពុំមានបណ្ណព័ត៌មានអ្នកបោះឆ្នោតទេ គាត់ត្រូវប្រាប់លេខរៀងរបស់ខ្លួនទៅលេខាធិការ ដើម្បីងាយស្រួលក្នុងការរកឈ្មោះក្នុងបញ្ជីបោះឆ្នោត។






លេខាធិការពិនិត្យផ្ទៀងផ្ទាត់ឈ្មោះ និងទិន្នន័យអ្នកបោះឆ្នោតក្នុងបញ្ជីបោះឆ្នោត

បន្ទាប់មក លេខាធិការប្រាប់ឱ្យអ្នកបោះឆ្នោតទៅទទួលយកសន្លឹកឆ្នោតពីអនុប្រធាន ដែលនៅអង្គុយខាងស្តាំដៃគាត់។

អនុប្រធាន បោះត្រាសម្ងាត់
នៅផ្នែកខាងខ្នងនៃសន្លឹកឆ្នោត រួចបត់សន្លឹកឆ្នោត
ជា ៤ផ្នត់។ បន្ទាប់មក ប្រគល់សន្លឹកឆ្នោត និង អ.ខ
ឬ ឯ.អ ព្រមទាំងបណ្ណព័ត៌មានអ្នកបោះឆ្នោត
(ប្រសិនបើមាន) ទៅឱ្យអ្នកបោះឆ្នោត។






អនុប្រធានបោះត្រាសម្ងាត់នៅផ្នែកខាងខ្នងនៃសន្លឹកឆ្នោត
និងប្រគល់សន្លឹកឆ្នោតទៅអ្នកបោះឆ្នោត

បន្ទាប់មក អ្នកបោះឆ្នោតត្រូវដើរទៅកាន់បន្ទប់សម្ងាត់
ណាមួយដែលទំនេរ ដើម្បីចូលទៅគូសសន្លឹកឆ្នោត។

នៅក្នុងបន្ទប់សម្ងាត់នេះ
គ្មានអ្នកណាដឹងថា អ្នកបោះឆ្នោតគូសសញ្ញាគាំទ្រឱ្យ
គណបក្សណាមួយឡើយ។

អ្នកបោះឆ្នោត ត្រូវគូសសញ្ញាគាំទ្រមួយ
នៅក្នុងប្រអប់បួនជ្រុងទ្រវែងនៃគណបក្សនយោបាយតែ ១គត់
ដែលអ្នកពេញចិត្ត ដោយប្រើប៊ិកដែលមានក្នុងបន្ទប់សម្ងាត់ស្រាប់
ឬក៏អាចប្រើប៊ិកផ្ទាល់ខ្លួន លើកលែងតែខ្មៅដៃ។





**អ្នកបោះឆ្នោតគូសសន្លឹកឆ្នោតក្នុងបន្ទប់សម្ងាត់**

មុននឹងចេញពីបន្ទប់សម្ងាត់
អ្នកបោះឆ្នោតត្រូវបត់សន្លឹកឆ្នោតតាមផ្នត់ដើម
រួចដើរទៅកាន់តុដាក់ហិបឆ្នោត លើកសន្លឹកឆ្នោត
ដែលបត់រួចហើយ និងមានត្រាសម្ងាត់នៅខាងខ្នង
បង្ហាញសមាជិកទី១ ដែលនៅក្បែរនោះ រួចស៊ក
សន្លឹកឆ្នោតតាមប្រឡោះតូចចូល
ទៅក្នុងហិបឆ្នោត។






**ការស៊កសន្លឹកឆ្នោតចូលទៅក្នុងហិបឆ្នោត**

បន្ទាប់មក អ្នកបោះឆ្នោតត្រូវជ្រលក់
ម្រាមចង្អុលដៃស្តាំទៅក្នុងដបទឹកខ្មៅលុបមិនជ្រះ។






ជួបសមាជិកទី១ ដើម្បីជ្រលក់ម្រាមចង្អុលដៃស្តាំ
ទៅក្នុងដបទឹកខ្មៅលុបមិនជ្រះ

បន្ទាប់មក អ្នកបោះឆ្នោត
ដើរចេញពីការិយាល័យបោះឆ្នោត ជាការស្រេច។






អ្នកបោះឆ្នោតដើរចេញពីការិយាល័យបោះឆ្នោត


១
យើងត្រូវដឹងថា សន្លឹកឆ្នោតយើង
គឺជាសន្លឹកឆ្នោតសម្ងាត់ គ្មានជនណាម្នាក់ដឹងថា
យើងបោះឆ្នោតជូនគណបក្សនយោបាយណាមួយឡើយ។
បើមានជនណាម្នាក់មកសួរយើងថាបោះឆ្នោតឱ្យគណបក្ស
ណាមួយនោះ យើងមិនត្រូវប្រាប់គេឡើយ
ព្រោះវាជាការសម្ងាត់របស់យើង។
២
អូ.....ខ្ញុំយល់ហើយ!